**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**'រ.ទ.ស.ភ'**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ២៥៣..ស..ស.៣

ភ្នំពេញ, ថ្ងៃទី ៣១ខែ តុលា ឆ្នាំ ២០១៧

**លិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា**
**ស្តីពីការធ្វើឃ្លាំងដាក់សម្ភារបន្ទប់រោងជាង និងជួសជុល**
**កែសម្រួលបន្ទប់ម៉ាស៊ីនបន្សាបភ្លើងដើម្បីដាក់គ្រឿងបន្លាស់**
**ម៉ាស៊ីនផលិតភ្លើងនៅរោងចក្រផលិតទឹកស្អាតភូមិព្រែក**

ខ្ញុំមានកិត្តិយសជម្រាបលោកស្រីប្រធានក្រុមហ៊ុន **អ៊ីវ៉ាន់ ស៊ីវីស** ថា ៖ ក្រោយពីការវាយតម្លៃលើឯកសារដាក់ដេញថ្លៃពីគ្រប់ក្រុមហ៊ុន ដែលបានបើកជាសាធារណៈកាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ដើម្បីធ្វើឃ្លាំងដាក់សម្ភារបន្ទប់រោងជាង និងជួសជុលកែសម្រួលបន្ទប់ម៉ាស៊ីនបន្សាបភ្លើងដើម្បីដាក់គ្រឿងបន្លាស់ម៉ាស៊ីនផលិតភ្លើងនៅរោងចក្រផលិតទឹកស្អាតភូមិព្រែក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានសម្រេចប្រគល់កិច្ចសន្យាជូនទៅក្រុមហ៊ុន **អ៊ីវ៉ាន់ ស៊ីវីស** ក្នុងតម្លៃកិច្ចសន្យាចំនួន ៨៩,១៩១,២០៥រៀល (ប៉ែតសិបប្រាំបួនលានមួយរយកៅសិបមួយពាន់ពីររយប្រាំរៀលគត់)។

អាស្រ័យហេតុនេះ សូមលោកស្រីប្រធានពិនិត្យ និងចុះហត្ថលេខាលើកិច្ចសន្យា ដែលបានជូនភ្ជាប់ រួចប្រគល់មករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានភ្ជាប់មកជាមួយនូវប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា (Performance Security) ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ក្នុងអំឡុងពេលមិនលើសពី១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានេះ។

សូមលោកស្រីប្រធានទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត.ជា វិសុទ្ធ**

ចម្លងជូន៖
-ក្រុមហ៊ុន អេស២ អេនជីនារីង & ឌីហ្សាញ
-ក្រុមហ៊ុន ខ្មែរ ទំនើប ពាណិជ្ជ & សំណង់